ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីតម្រូបព្រៃឈើឆ្នាំ២០០២ ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៣ ៤៩៥ ហិកតា នៅឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ១៧៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡុងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ៥៤០ លស ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ចេញនិងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបទំហំ ៣៤៩៥ហិកតា (បីពាន់បួនរយកៅសិបប្រាំហិកតា) ដែលក្នុងនោះកាត់ចេញពីដែទីគម្របព្រៃឈើឆ្នាំ២០០២ នូវផ្ទៃដីទំហំ ២៩១ ហិកតា និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ( លិខិតលេខ ៨៥២ សជណ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) នូវផ្ទៃដីទំហំ ៣២០៤ ហិកតា មានទីតាំងស្ថិតនៅឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាំងថ្មីម ចំនួន ២៩៦ គ្រួសារ ភូមិតាំងត្រពាំង ចំនួន ២៩៦ គ្រួសារ ភូមិថ្នល់ចំនួន ១៩៨ គ្រួសារ ភូមិក្រាំងកកោះ ចំនួន ១៩៧ គ្រួសារ និងភូមិទឹកជ្រាប ចំនួន ៩១ គ្រួសារ ។

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*